ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៣ សសរ

សេចក្តីសំរេច

ស្តីពី

ការកែសំរួលសមាសភាព គណៈកម្មការចំរុះអន្តរក្រសួង ដើម្បី ស្រាវជ្រាវករណីផ្ទុះអាវុធ ពេលអនុវត្តសេចក្តីសំរេចរបស់តុលាការ នៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញសេចក្តីសំរេច លេខ ៣០ សសរ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពី ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីស្រាវជ្រាវករណីផ្ទុះអាវុធ ពេលអនុវត្តសេចក្តីសំរេចរបស់តុលាការ នៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

-យោងតាមការចាំបាច់ និង តាមសំណើរបស់ប្រធានគណៈកម្មការចំរុះអន្តរក្រសួង

សម្រេច

ប្រការ១ : ត្រូវបានរៀបចំកែសំរួលសមាសភាព គណៈកម្មការចំរុះអន្តរក្រសួងដែលមានចែងក្នុងប្រការ១នៃសេចក្តីសំរេចលេខ ៣០ សសរ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៦ ដើម្បីស្រាវជ្រាវករណីផ្ទុះអាវុធពេលអនុវត្ត

www.pheakdeylaw.com

សេចក្តីសំរេចរបស់តុលាការបង្គាប់ឱ្យមានស្លាប់ និងរបួសដល់ប្រជាពលរដ្ឋនៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដោយប្រគល់ភារកិច្ចជូន ឯកឧត្តម **ហ៊ី សោភា** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ធ្វើជា **អនុប្រធានគណៈកម្មការ** ជំនួស ឯកឧត្តម ទូត លុច ។

ប្រការ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានស្ថាប័នពាក់ព័ន្ធ ប្រធានគណៈកម្មការចំរុះអន្តរក្រសួង និង ឯកឧត្តម ដែលមាន ឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ទុលា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com